ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

## សូមគោរពជូន

## ឯកឧត្តម នាយឧត្តមសេនីយ៍ វង្ស ពិសេន និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ

ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេក ក្រោយពីបានទទួលដំណឹងថា ឧបាសិកា **ឈឹម ឆោម** ដែលត្រូវជាម្តាយក្មេក ម្តាយបង្កើត ជីដូន និងជាជីដូនទួតជាទីស្រឡាញ់ បានទទួលមរណភាពកាលពីថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០ ក្នុងជន្មាយុ ៨២ឆ្នាំ ដោយរោគាពាធ។

ក្នុងវេលាប្រកបដោយក្តីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុតជាមួយ **ឯកឧត្តម នាយឧត្តមសេនីយ៍ និង លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ ឧបាសិកា **ឈឹម ឆោម** ដែលត្រូវជាម្តាយក្មេក ម្តាយបង្កើត ជីដូន និងជាជីដូនទួត ដែលប្រកបដោយព្រហ្មវិហារធម៌ដ៏ឧត្តុង្គឧត្តម ហើយក៏ជាការបាត់បង់នូវមហាកម្លាំងសាមគ្គីនៅក្នុងចលនាពុទ្ធសាសនូបត្ថម្ភកផងដែរ។

ក្នុងឱកាសពោរពេញដោយសេចក្តីទុក្ខក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធឧបាសិកា **ឈឹម ឆោម** សូមបានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ និង លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ៩កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ សុខា